ចំណាប់អារម្មណ៍របស់លោក **ជួប សុខចំរើន** នាយករងអង្គការខាណា និងជាអនុប្រធាន
គ្រប់គ្រងគម្រោងHIV/AIDS Flagship នៅក្នុងកិច្ចប្រជុំសម្របសម្រួលជាន់ខ្ពស់

ស្ដីពីការអនុវត្តបទអន្តរាគមន៍បង្ការមេរោគអេដស៍ និង ជំងឺអេដស៍
ក្នុងចំណោមបុរសស្រឡាញ់បុរស
ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣ នៅសណ្ឋាគារសាន់វេ

- សូមគោរពឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តមវេជ្ជបណ្ឌិត **តៃង គន្ធី** អគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- លោកជំទាវ **ម៉ក់ វណ្ណាស៊ីថា** អភិបាលរងរាជធានីភ្នំពេញ និង ជាប្រធានគណៈកម្មាការអេដស៍រាជធានីភ្នំពេញ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងអាជ្ញាធរមូលដ្ឋាននៃរាជធានីភ្នំពេញ
- លោក លោកស្រី តំណាង អង្គការជាតិ និង អន្តរជាតិ ព្រមទាំង
- លោក លោកស្រី ដែលជាក្រុមបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់ ជាទីគោរពនិងជាទីមេត្រី !

ក្នុងនាមអង្គការខាណា និងជាតំណាងសម្ព័ន្ធអ្នកអនុវត្តគម្រោងផ្លេកស៊ីប ខ្ញុំសូមអនុញ្ញាត និងសូមសម្តែងនូវមោទនភាពរីករាយដែលទទួលបានការផ្តល់ឱកាសឱ្យចូលរួមថ្លែងយោបល់ក្នុងកិច្ចប្រជុំសម្របសម្រួលជាន់ខ្ពស់ស្តីពីការអនុវត្តន៍បទអន្តរាគមន៍បង្ការមេរោគអេដស៍ និង ជំងឺអេដស៍ ក្នុងចំណោមបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់ ដែលបានរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សហការជាមួយអង្គការសេវាសង្គមសុខភាពបុរស ដែលជាអង្គការដៃគូអនុវត្តគម្រោងផ្លេកស៊ីប ក្រោមមូលនិធិគាំទ្ររបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។

ជាមួយគ្នាផងដែរខ្ញុំក៏សូមវាយតម្លៃខ្ពស់ សម្រាប់ការរៀបចំឱ្យមានកិច្ចប្រជុំដែលមានសារៈសំខាន់ ក្រោមការចូលរួមពីគ្រប់ភាគីអ្នកពាក់ព័ន្ធដើម្បីឱ្យការឆ្លើយតបចំពោះមេរោគអេដស៍ជាលក្ខណៈពហុវិស័យបន្តអនុវត្តកាន់តែមានប្រសិទ្ធភាព ចំគោលដៅ និងទទួលបានលទ្ធផលដូចដែលកម្ពុជាបានសន្យាជាលក្ខណៈនយោបាយក្នុងការសម្រេចបានគោលដៅបីសូន្យ ដែលគ្មានការឆ្លងថ្មី គ្មានការរើសអើង និងគ្មានការស្លាប់ដោយជំងឺអេដស៍នាបំណាច់ឆ្នាំ ២០១៥ ។ អង្គការខាណា និងគម្រោងផ្លេកស៊ីប ក៏សូមយកឱកាសនេះថ្លែងអំណរគុណយ៉ាង ជ្រាលជ្រៅសម្រាប់ការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសការដឹកនាំរបស់អាជ្ញាធរ ជាតិប្រយុទ្ធនឹងជំងឺអេដស៍ ការចូលរួមរបស់ក្រសួងមន្ទីរពាក់ព័ន្ធ សមត្ថកិច្ចមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍន៍ និងជាពិសេសការចូលរួមរបស់សហគមន៍ ដូចដែលមានវត្តមានក្នុងកិច្ចប្រជុំនាថ្ងៃនេះស្រាប់ ក្នុងការជម្រុញអោយកម្ពុជាទទួលបានជោគជ័យក្នុងការកាត់បន្ថយ អត្រាឆ្លងមេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅមកនៅក្រោមមួយភាគរយ (0.6%) នាឆ្នាំ ២០១៣ និងបន្តធ្លាក់ចុះទៀតក្នុងឆ្នាំ២០១៥ខាងមុខ។

អង្គការខាណា និងគម្រោងផ្លេកស៊ីប ក្នុងនាមជាដៃគូរបស់រាជរដ្ឋាភិបាលកម្ពុជានឹងបន្តការខិតខំ និងការសហការដ៏ជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាននិងសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ដើម្បីស្វែងរកនូវគំនិតផ្តួចផ្តើមនិងយុទ្ធសាស្រ្តថ្មីៗ ដែលជាគោលបំណងដ៏សំខាន់របស់គម្រោងផ្លេកស៊ីប ក្នុងការបង្ការ ការថែទាំ និងការព្យាបាល ពាក់ព័ន្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់ រួមមានក្រុមបុរសស្រឡាញ់បុរស ក្រុមស្រីស្រស់ ក្រុមស្ត្រីបំរើការនៅតាមគ្រឹះស្ថានកំសាន្ត និងក្រុមអ្នកប្រើប្រាស់និងចាក់គ្រឿងញៀន ដែលមានអត្រាឆ្លងខ្ពស់នៅឡើយបើធៀបជាមួយនឹងក្រុមប្រជាជនទូទៅនៅកម្ពុជា។

ដូច្នេះសម្រាប់ពីពេលនេះដល់បំណាច់ឆ្នាំ២០១៥ ដើម្បីឱ្យយើងអាចយកជ័យជម្នះចំពោះមេរោគអេដស៍ដូចដែលបានកំណត់នោះ ជាពិសេសសម្រាប់ការបង្ការនិងលុបបំបាត់ ការចម្លងថ្មីនៃមេរោគអេដស៍ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់ ដែល ជាប្រធានបទសំខាន់នៃការពិភាក្សានាថ្ងៃនេះ លុះត្រាតែ ៖

1. ជម្រុញ និងបង្កភាពងាយស្រួលឱ្យក្រុមបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់បន្តទទួលបានសេវាអប់រំ មធ្យោបាយបង្ការរួមមានស្រោមអនាម័យ និងទឹករំអិល

2. ផ្តល់ការគាំទ្រ និងការលើកទឹកចិត្តឱ្យក្រុមបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់ទទួលបានការផ្តល់ប្រឹក្សានិងរក្សាការសម្ងាត់ និងទទួលយកការធ្វើតេស្តឈាមដោយជោះចុងម្រាមដៃដែលមានលក្ខណៈរហ័ស និងបង្ហាញលទ្ធផលលឿន សម្រាប់ឱ្យគេដឹងអំពីស្ថានភាពរបស់គេពាក់ព័ន្ធនឹងមេរោគអេដស៍។
3. ជម្រុញ គាំទ្រ លើកទឹកចិត្ត និងបញ្ជូនក្រុមបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់ ដែលមានលទ្ធផលតេស្តវិជ្ជមានទទួលបានការព្យាបាលដោយថ្នាំប្រឆាំងមេរោគអេដស៍ជាបន្ទាន់ និងទទួលបានការតាមដាន និងការថែទាំ ដើម្បីឱ្យការព្យាបាលបានជាប់លាប់ និងមានប្រសិទ្ធភាព។
4. បង្ក និងបន្តផ្តល់ការគាំទ្រពីសំណាក់អាជ្ញាធរមូលដ្ឋាន សមត្ថកិច្ចពាក់ព័ន្ធនៅគ្រប់លំដាប់ថ្នាក់ឱ្យមានការផ្លាស់ប្តូរយោបល់រវាងអ្នកផ្តល់សេវា និងអ្នកទទួលសេវា ដើម្បីធានានូវតម្លាភាពព័ត៌មាន រកឃើញចំណុចអសកម្ម និងកំណត់បានដំណោះស្រាយដែលមានការព្រមព្រៀង និងមានការចូលរួម។
5. បង្ក និងផ្តល់ការគាំទ្រក្នុងការជម្រុញនិងរកឱ្យឃើញនូវការបោះបង់ការព្យាបាល និងការស្លាប់ដែលបណ្តាលមកពីមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមប្រជាជនប្រឈមមុខខ្ពស់ ជាពិសេសក្រុមបុរសស្រឡាញ់បុរសនិងក្រុមស្រីស្រស់
6. បង្ក សម្របសម្រួល និងជម្រុញឱ្យមានការចូលរួមដោយផ្ទាល់ពីសំណាក់ម្ចាស់គ្រឹះស្ថានកំសាន្តសប្បាយ រួមមានក្លឹបរាត្រី ក្នុងការអនុវត្តន៍គោលនយោបាយស្រោមអនាម័យមួយរយភាគរយ និងជាពិសេសឱ្យមានការបង្ហាញនិងការអប់រំអំពីស្រោមអនាម័យនៅកន្លែងការងារសម្រាប់ក្រុមបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់។
7. បញ្ឈប់ការធ្វើទារុណកម្ម ការធ្វើទុក្ខទោស និងការប្រមាថមាក់ងាយចំពោះក្រុមបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់ដោយគ្រាន់តែស្ថានភាពឬកពារ និងអាកប្បកិរិយាមានលក្ខណៈខុសប្លែកអំពីប្រជាជនទូទៅ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី!

ក្នុងនាមអង្គការខាណា និងគម្រោងផ្លេកស៊ីប ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរ

គុណយ៉ាងជ្រាលជ្រៅដែលបានផ្តល់ឱកាសឱ្យយើងខ្ញុំបានថ្លែងយោបល់ក្នុងកិច្ចប្រជុំសម្របសម្រួលដ៏ពិសេសនាថ្ងៃនេះ។ យើងខ្ញុំសង្ឃឹមថាមតិយោបល់ដែលយើងខ្ញុំ បានថ្លែងនិងបានចូលរួមក្នុងកិច្ចប្រជុំនេះ នឹងត្រូវបានប្រើប្រាស់ និងបំផ្លែង ជាសកម្មភាពជាក់ស្តែងដើម្បីប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ក្នុងការបង្ការទប់ស្កាត់ និងលុបបំបាត់ ការឆ្លងថ្មីនៃមេរោគអេដស៍ដូចដែលយើងបានរំពឹងទុក។

ជាទីបញ្ចប់ សូមគោរពជូនពរឯកឧត្តមទេសរដ្ឋមន្រ្តី ឯកឧត្តមលោកជំទាវ លោក លោកស្រីក្នុងឱកាសឆ្នាំថ្មីដែលនឹងឈានមកដល់នាពេលខាងមុខដ៏ខ្លី សូមទទួលបានជោគជ័យ សុខភាពល្អ សុភមង្គល និងជ័យជំនះនៅគ្រប់ភារកិច្ច៕

សូមអរគុណ៕